# ដំណាំម្រេច



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម

*Loan 2022-CAM(SF)*

២០០៨

# ដំណាំម្រេច

ដំណាំម្រេច ជាដំណាំដុះលូតលាស់យូរអង្វែង មានលក្ខណៈជារុក្ខជាតិវល្លិនៅក្នុងតំបន់ត្រូពិចក្ដៅហើយ ដែលមានកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំពី ២០០០-២៥០០ មីលីម៉ែត្រ



ឬច្រើនជាងនេះ ។ នៅកម្ពុជា ដំណាំម្រេច ជាដំណាំកសិ-ឧស្សាហកម្មសំខាន់សម្រាប់បង្កើនប្រាក់ចំណូលក្នុងគ្រួសារ និងសេដ្ឋកិច្ចជាតិ ។

ដំណាំម្រេចបានចាប់ផ្ដើមដាំនៅកម្ពុជា តាំងពីសតវត្សន៍ទី ១៩ គឺក្នុងឆ្នាំ ១៨៤០ ដែលមានប្រភពមកពីខេត្តហាយណាន់ ប្រទេសចិន ។ នៅកម្ពុជា ម្រេចគឺជាគ្រឿងទេសមួយសំខាន់ មនុស្សយើងបរិភោគជាអាហារ និងប្រើជាវត្ថុធាតុដើមសម្រាប់ធ្វើឱសថព្យាបាលជម្ងឺ ធ្វើគ្រឿងក្រអូប និងធ្វើថ្នាំកំចាត់សត្វល្អិត ដូចជាសត្វដែលរស់នៅលើសំភារៈធ្វើពីរោមសត្វ និងខ្មៀន ។ ដោយនៅក្នុងផ្លែមានសារជាតិ អាល់កាឡូអ៊ីត ដែលរួមមាន ពីប៉េរីន ពីប៉េរ៉េទីន សាវីរីន គូម៉ាប៉េរីន គីមហ្វេរ៉ូល ហ្គេសេទីន អាស៊ីតកាហ្វេអ៊ិច ហ្គីនីនស៊ីន ពីប៉េរ៉ាមីន ឌីអីដ្រូពីពែរស៊ីដ បេតា-ស៊ីតូស្តេរ៉ូល និងសារធាតុប្រេង ដែលមានទែរប៉ែន ហ្វេលង់ដ្រែន ការីអូហ្វីឡែន និង

អ៊ុកសីដការីអូហ៊្វីឡេនជាដើម ។

ដំណាំម្រេចជាដំណាំបន្តពូជ និងពង្រីកដោយមើម ដោយកាត់ថ្នាំងផ្នែកខាងលើនៃដើម ដែលមានអាយុចាប់ពីដប់ប្រាំបីខែឡើង ។





## ១_ស្ថានភាពដំណាំម្រេច

### អំពីតំបន់ដាំដុះ :

នៅកម្ពុជា ដំណាំម្រេចត្រូវបានដាំដុះនៅតំបនខ្ពង់រាប និងតំបន់មាត់សមុទ្រ លើប្រភេទដីស្រស់ទឹកល្អ ដូចជានៅក្នុងខេត្តកំពត ក្រុងព្រះសីហនុ ខេត្តកោះកុង ខេត្តកំពង់ចាម មណ្ឌលគិរី និងខេត្តតាកែវ ។ មុនឆ្នាំ ១៩៧០ ផ្ទៃដីដីដាំដុះមានប្រមាណ ៨៦០ ហិកតា និងមានបរិមាណផលសរុបចំនួន ២,៥២០ តោន នៅខេត្តកំពត កោះកុង ក្រុងព្រះសីហនុ និងខេត្តកំពង់ចាម ។



បច្ចុប្បន្ននេះ តំបន់ដាំម្រេចបានពង្រីកទៅខេត្តមួយចំនួន ដូចជាខេត្តមណ្ឌលគិរី និងខេត្តតាកែវជាដើមដែលមានផ្ទៃដីសរុបប្រមាណជាង ១000 ហិកតា ។ លទ្ធភាពដីអាចពង្រីកដល់ជាង ៤000 ហិកតា បើមានទីផ្សារល្អ ។

**អំពីពូជ :**

ដំណាំម្រេចដែលបានធ្វើការដាំដុះនៅកម្ពុជា មានពូជពីរប្រភេទគឺពូជឡាំពុង (LAMPONG) មានប្រភពមកពីប្រទេសឥណ្ឌូនេស៊ី ដែលមានស្លឹកធំ ថ្នាំងវែង ក្ងរវែង និងផ្លែតូច ។ និងពូជកំចាយ (KAMCHAY)មានប្រភពដើមមិនច្បាស់លាស់ហើយ មានស្លឹកតូច ថ្នាំងខ្លី និងផ្លែធំ ។

